**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ស្ពឺ**

លេខ ៖ ៤១១/២៣ ស.ជ.ណ

ថ្ងៃ ចន្ទ ៣ រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពង់ស្ពឺ ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០២៣

# សេចក្តីជូនដំណឹង
## ស្តីពី
## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២៤

រដ្ឋបាលខេត្តកំពង់ស្ពឺ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២៤ សម្រាប់ការចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២៤។

អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា៣ប្រភេទដូចជា៖

- **ប្រភេទទី១** ៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អគារ និងការងារបេតុង)
- **ប្រភេទទី២** ៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ទ្វារទឹកខ្នាតតូច លូមូល)
- **ប្រភេទទី៣** ៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

- អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ដូចជា ប្រភេទទី១ ត្រូវមាន(ឧបករណ៍សម្រាប់លាយបេតុង, ម៉ាស៊ីនភ្លើង, ឧបករណ៍រំញ័របេតុង) ប្រភេទទី២ ត្រូវមាន(អ៊ិចស្កាវ៉ាទ័រ, ប៊ុលដូហ្ស៊ែរ ឬនីវ៉េល័រ, រូឡូបង្ហាប់, រថយន្តដឹកដី) ប្រភេទទី៣ ត្រូវមាន(ឧបករណ៍សម្រាប់ខួងអណ្តូង១កំប្លេ)។ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះ ក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ត្រូវមានបទពិសោធន៍អនុវត្តគម្រោងយ៉ាងតិច០២គម្រោង ទាក់ទងទៅនឹងប្រភេទនីមួយៗដែលបានស្នើសុំក្នុងអំឡុងរយៈពេល៥ឆ្នាំចុងក្រោយ។

- គណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច។

- អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណា ក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ សូមអ្នកទទួលការទាំងអស់ដែលមានបំណងចុះឈ្មោះ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃអង្គារ ទី៣១ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង១៧ និង០០នាទី។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ៕

*សម្គាល់៖ អាស័យដ្ឋានទំនាក់ទំនង ទីចាត់ការផែនការ និងវិនិយោគ ទូរស័ព្ទលេខ ០១៦ ៣៣៣ ៩៥៤។*

**អភិបាល នៃគណៈអភិបាលខេត្ត**

**ឌី សំណាង**

**ចម្លងជូន ៖**
-ក្រសួងមហាផ្ទៃ
-លេខាធិការដ្ឋាន គ.ជ.អ.ប
"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ